ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១១.១២ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៣-១៩៩៦- ព្រះរាជក្រឹត្យ ជស/រកត/០៣៩៦/១០ បង្កើតក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ មានឈ្មោះថា អគ្គិសនីកម្ពុជា ៥៥០

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៦ តែងតាំងលោក **ថៃ សេង ឡុង** ជាឧកញ៉ា ៥៥២

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៧ តែងតាំងលោក **គិត ម៉េង** ជាឧកញ៉ា ៥៥៣

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៨ តែងតាំងលោក **ស្រី ឈាងឈាង** ជាឧកញ៉ា ៥៥៤

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យលេខ នស/រកត/ ០៣៩៦/១៩ ស្តីពីការលើកលែងទោស និង បន្ធូរទោសអោយទណ្ឌិត ៥៥៥

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២០ តែងតាំងឯកឧត្តម **ខែកឡឺរង់** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៥៥៧

១៣-៣-១៩៩៦- ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២១ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ចំពោះសពលោកវរសេនីយ៍ឯក **ខាន់ គីមស៊ន** ៥៥៨

១៥–៣–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២២ តែងតាំងឯកឧត្តម **ហោ ណាំហុង** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋ បារាំង ៥៦០

២១–៣–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២៣ តែងតាំង ឯកឧត្តម **ជា រឡឹឈុត** ជាប្រតិភូរាជរដ្ឋាភិបាល ប្រចាំទីក្រុងកែប ៥៦០

II - ឯកសារគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

២៧–៣–១៩៩៦– អនុក្រឹត្យលេខ ១០ អនក្រ. បក ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ៥៦១

២៩–៣–១៩៩៦– អនុក្រឹត្យលេខ ១១ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់វារីអគ្គិសនីស្ទឹងមេទឹក (មណាម) នៃព្រះរាជាណាចក្រកម្ពុជា ៥៦៨

២៩–៣–១៩៩៦– អនុក្រឹត្យលេខ ១២ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោងស្តារ និងកែលំអអាកាសយានដ្ឋាន ខេត្តសៀមរាប ៥៧១

១៩–៣–១៩៩៦– អនុក្រឹត្យលេខ ៤២ អនក្រ. តត ស្តីពីការផ្លាស់មន្ត្រីរាជការ ៥៧៥

២១–៣–១៩៩៦– អនុក្រឹត្យលេខ ៤៣ អនក្រ. តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៧៦

២១–៣–១៩៩៦– អនុក្រឹត្យលេខ ៤៤ អនក្រ. តត ស្តីពីការកែសំរួលឋានន្តរសក្តិ និង ផ្តល់អត្តលេខយោធិន ៥៧៧

២២–៣–១៩៩៦– អនុក្រឹត្យលេខ ៤៥ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៧៨

២២–៣–១៩៩៦– អនុក្រឹត្យលេខ ៤៦ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៧៩

២២–៣–១៩៩៦– អនុក្រឹត្យលេខ ៤៧ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨០

២២-៣-១៩៩៦- អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨២
២២-៣-១៩៩៦- អនុក្រឹត្យលេខ ៥០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨៣
២២-៣-១៩៩៦- អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៨៥
២៨-៣-១៩៩៦- អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌនាយទាហាន ៥៨៦

២ - សេចក្តីសំរេច

១៦-៣-១៩៩៦- សេចក្តីសំរេចលេខ ០៦ សសរ ស្តីពីការប្រគល់ភារកិច្ច បណ្តោះអាសន្ន ៥៨៧
២០-៣-១៩៩៦- សេចក្តីសំរេចលេខ ០៧ សសរ ស្តីពីការបង្កើតក្រុមការងារ សំរាប់ធ្វើការងារជាមួយក្រុមការងារសហគមន៍អឺរ៉ុប លើបញ្ហា នាំចេញសំលៀកបំពាក់ទៅអឺរ៉ុប ៥៨៨
២៧-៣-១៩៩៦- សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការបង្កើតគណៈកម្មការ បង្ក្រាបការផលិត និងនាំចូលរូបិយវត្ថុក្លែងក្លាយគ្រប់ប្រភេទ ៥៩១
២៧-៣-១៩៩៦- សេចក្តីសំរេចលេខ ០៩ សសរ លិខិតសរសើរ ៥៩៣
២៨-៣-១៩៩៦- សេចក្តីសំរេចលេខ ១០ សសរ ស្តីពីការផ្ទេរសិទ្ធិ ៥៩៣
២៩-៣-១៩៩៦- សេចក្តីសំរេចលេខ ១១ សសរ ស្តីពីការបង្កើតគណៈកម្មការ ពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល ៥៩៤

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៧-៣-១៩៩៦- ប្រកាសលេខ ១៩០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ស្រី ចាន់ណារី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការ

	អាជីវកម្មកាត់ដេរសំលៀកបំពាក់	៥៩៦
៧-៣-១៩៩៦-	ប្រកាសលេខ ១៩១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ម៉ៅ រ៉ាស៊ីន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម	៥៩៦
២៧-៣-១៩៩៦-	ប្រកាសលេខ ១៩២ ផក.ប្រក អនុញ្ញាអោយអ្នកស្រី **គីម ឌុំក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋក្បឿង	៥៩៧
២៧-៣-១៩៩៦-	ប្រកាសលេខ ១៩៣ ផក.ប្រក អនុញ្ញាអោយលោក **ម៉ៅ ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ	៥៩៨
២៧-៣-១៩៩៦-	ប្រកាសលេខ ១៩៤ ផក.ប្រក អនុញ្ញាអោយលោក **លឹម ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឡផលិតឥដ្ឋក្បឿង	៥៩៨
២៧-៣-១៩៩៦-	ប្រកាសលេខ ១៩៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ឃុត ស៊ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋគ្រឿង	៥៩៩
២៧-៣-១៩៩៦-	ប្រកាសលេខ ១៩៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **វ៉ែ យ៉ាត** ជនជាតិខ្មែរសញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម	៥៩៩
២៨-៣-១៩៩៦-	ប្រកាសលេខ ១៩៨ ផក.ប្រក អនុញ្ញាតអោយលោក **លី សៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ	៦០០
២៨-៣-១៩៩៦-	ប្រកាសលេខ ១៩៩ ផក.ប្រក អនុញ្ញាតអោយលោក **ឡាច ស្រួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ	៦០០

២៨-៣-១៩៩៦- ប្រកាសលេខ ២០០ ផក.ប្រក អនុញ្ញាតអោយលោក **គីងឌី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥១សេះ ៦០១

២៨-៣-១៩៩៦- ប្រកាសលេខ ២០១ ផក.ប្រក អនុញ្ញាតអោយលោក **ទ៉េង សំអាត** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មផលិតជីតីមី ១៦.២០.០០ ៦០២

២៨-៣-១៩៩៦- ប្រកាសលេខ ២០៥ ផក.ប្រក អនុញ្ញាតអោយលោក **ឈុន ហួត** ជនជាតិខ្មែរ សញ្ញាតកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋក្បឿង ៦០២

២៨-៣-១៩៩៦- ប្រកាសលេខ ២០៦ ផក.ប្រក អនុញ្ញាតអោយ **ខូច សម្បត្តិ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋក្បឿង ៦០៣

២៨-៣-១៩៩៦- ប្រកាសលេខ ២០៧ ផក.ប្រក អនុញ្ញាតអោយលោក **កែន នុន** ជនជាតិខ្មែរសញ្ញាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង ៦០៣

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៨-៣-១៩៩៦- ប្រកាសលេខ ២៧៨ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យស្ទោងទៅជាវិទ្យាល័យស្ទោង ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ៦០៤

១៩-៣-១៩៩៦- ប្រកាសលេខ ២៨៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ទឹកឃ្លាំង ៦០៥

២១-៣-១៩៩៦- ប្រកាសលេខ ២៨៦ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ កោះសូទិន ទៅជា «អនុវិទ្យាល័យ **សាយ ឈុំ** កោះសូទិន »ស្ថិតនៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ៦០៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ និង អំពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល

ត្រាស់បង្គាប់

មាត្រា ១ : បង្កើតក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ មានឈ្មោះថាអគ្គិសនីកម្ពុជា សរសេរ កាត់ អ.ក ដែលមានភារកិច្ចផលិតបញ្ជូន និងចែកចាយថាមពល

អគ្គិសនី ទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការប្រព្រឹត្តិទៅនឹងទំនាក់ទំនងរវាងអគ្គិសនីកម្ពុជា និងរាជរដ្ឋាភិបាលត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២ : អគ្គិសនីកម្ពុជាជានីតិបុគ្គលមានស្វ័យភាពផ្នែកគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុមានគោលដៅពាណិជ្ជកម្ម និងមានសិទ្ធិ និងការទទួលខុសត្រូវកំណត់ដោយច្បាប់ ។ អគ្គិសនីកម្ពុជាទទួលខុសត្រូវដោយផ្ទាល់ចំពោះកំរៃ និងការបង់ខាតព្រមទាំងបំណុលទាំងអស់ត្រឹមកំរិតនៃតំលៃ ធនធានរបស់ខ្លួន ។ ក្នុងតួនាទីជាម្ចាស់នៃ អគ្គិសនីកម្ពុជា រដ្ឋទទួលខុសត្រូវក្នុងកំរិតត្រឹមបរិមាណទុនដែលរដ្ឋបានដាក់ចូលជា ភាគហ៊ុននៃដើមទុនរបស់អគ្គិសនីកម្ពុជាតែប៉ុណ្ណោះ ។

មាត្រា ៣ : អាជ្ញាធរអគ្គិសនីកម្ពុជា នឹងត្រូវបង្កើតដោយច្បាប់ ដើម្បីបង្កើនប្រសិទ្ធភាព ព្រមទាំងភាពបរិបូណ៌នៃសេវាអគ្គិសនីនៅកម្ពុជាតាមរយៈការជំរុញអោយមានកម្មសិទ្ធិ និងការប្រកួតប្រជែងរវាង ឯកជនក្នុងកិច្ចផលិតថាមពលអគ្គិសនី ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង ដោយព្រះរាជបញ្ជា

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

ពូ សុធីរៈ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១

ព្រះហស្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និងត្រា

ហ៊ុន សែន

ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៦/១៦

ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ថៃ សេងឡុង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក គិត មេង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៨

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ស្រី ណាងឈាង

ជា

ឧកញ៉ា

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្ដលេខា

នរោត្ដម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/១៩
ស្តីពីការលើកលែងទោស និង បន្ធូរបន្ថយទោសអោយទណ្ឌិត

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

បានឃើញក្រឹត្យ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៨៨

ត្រាស់បង្គាប់

មាត្រា ១. : ត្រូវលើកលែងទោសទណ្ឌិតចំនួន ១០នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេល រងទោស ដូចរាយនាមខាងក្រោមនេះ :

១_ទណ្ឌិតឈ្មោះ **យោគ ផាន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំតាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩១ របស់តុលាការយោធា។

២_ទណ្ឌិតឈ្មោះ **វ៉ាន់ ឆួក** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១១ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩១ របស់តុលាការយោធា ។

៣_ទណ្ឌិតឈ្មោះ **ម៉ុក ឈិន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩១ របស់តុលាការយោធា ។

៤_ទណ្ឌិតឈ្មោះ **ប៊ុន ណារ៉េត** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩២ របស់តុលាការយោធា។

៥_ទណ្ឌិតឈ្មោះ **ស៊ិន សាខន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩០ របស់តុលាការយោធា។

៦_ទណ្ឌិតឈ្មោះ **សុខ ស្រៀង** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩០ របស់តុលាការយោធា ។

៧_ទណ្ឌិតឈ្មោះ **ទៅ ខាន់** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩០ របស់តុលាការយោធា ។

៨_ទណ្ឌិតឈ្មោះ **ស៊ិន សៅ** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩២ របស់តុលាការយោធា ។

៩_ទណ្ឌិតឈ្មោះ **កេត ទុំន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៨៧ របស់តុលាការយោធា ។

១០_ទណ្ឌិតឈ្មោះ **ឌី ហ៊ិន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩១ របស់តុលាការយោធា ។

មាត្រា ២ : ត្រូវបន្ថយទោសរយៈពេល ០៩ខែ ឱ្យទណ្ឌិតចំនួន ០១នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈរងទោស :

_ទណ្ឌិតឈ្មោះ **ផាត់ នឹម** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩១ របស់តុលាការយោធា ។

មាត្រា ៣ : ត្រូវបន្ថយទោសរយៈពេល ០៦ខែ ឱ្យទណ្ឌិតចំនួន ០១នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈ រងទោស :

_ទណ្ឌិតឈ្មោះ ជុះ លី ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ០៩ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩២ របស់តុលាការយោធា ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ មានអនុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

មាត្រា ៥ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យឱ្យបានជាស្ថាពរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ខែក ឡឺរ៉េង** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឱ្យទទួល

បន្ទុកបន្ថែមមុខងារ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហភាពមី-យ៉ាន់មារ ដែលមាននិវេសនដ្ឋាននៅរៀងចន្ទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយត្រី** ជាកិច្ចបច្ចាមរណៈ ជូនចំពោះសព លោកវរសេនីយឯក **ចាន់ គីមស៊ីន** អត្តលេខ ០០០៤៥៤ មេបញ្ជាការកងពលតូចទ័ពព្រៃទី ១ អគ្គសេនាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ ... ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

ប្រកាសបង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ហោ ណាំហុង** ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង និងសហគមន៍អឺរ៉ុប ប៊ែលហ្ស៊ិក អូទ្រីស និង ហ្សឺណែវ ឱ្យទទួលបន្ទុកបន្ថែមមុខងារជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសសេណេហ្គាល ដែលមាននិវេសនដ្ឋាននៅប៉ារីស ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៣៩៦/២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៦

ប្រកាសបង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ជា រិទ្ធីឈុត** ជាប្រតិភូរាជរដ្ឋាភិបាល ប្រចាំទីក្រុងកែប ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ត្រូវទុកជានិរាករណ៍នូវព្រះរាជក្រឹត្យ នស/រកត/០៥៩៤/៣៣ស្ទួន ចុះថ្ងៃទី ១៧_៥_១៩៩៤ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៨៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៨៦

អនុក្រឹត្យលេខ ១០ អនក្រ.បក

ស្តីពីការអនុវត្តន៍

របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាព

ការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និង របបសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន
- តាមសេចក្តីបង្គំទូលស្នើសុំ និងស្នើសុំអំពី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា ១ ._យោធិនទាំង ២ ភេទនៃកងយោធពលខេមរភូមិន្ទ អាចទទួលរបបសោធននិវត្តន៍ជាប្រចាំខែបានលុះត្រាតែបានបំពេញតាមលក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ១ និង មាត្រា ២ ជំពូក ទី ១ នៃព្រះរាជក្រម ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

ចំពោះរយៈពេលដែលយោធិនទាំង ២ ភេទបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព ដូចមានចែងក្នុងមាត្រា ២ ចំណុច ក (២ ៣ ៤) និង ចំណុច ខ (២) ជំពូកទី ១ នៃព្រះរាជក្រម គឺជារយៈពេលដែលបានបំរើការងារជាប់រហូត ហើយបានបំពេញតាមលក្ខខ័ណ្ឌនីមួយៗនោះ ទើបអាចទទួលរបបសោធននិវត្តន៍បាន ។

មាត្រា ២ ._របៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាពរបស់យោធិនម្នាក់ៗ នៃកងយោធពលខេមរភូមិន្ទ ដូចមានចែងនៅ ក្នុងមាត្រា ៣ ជំពូកទី ១ នៃព្រះរាជក្រម ត្រូវបានកំណត់ដូចខាងក្រោម ÷

១_របៀបគិតរយៈពេលបំរើការងារ :

ការគិតរយៈពេលបំរើការងារ គឺបានគិតរួមទាំងរយៈពេលបំរើការងារគ្រប់របបសង្គម "បើមាន "និងរយៈពេលបំរើការងារស៊ីវិល និងកងយោធពលខេមរភូមិន្ទ ។

ក_ត្រូវចាត់ទុកជារយៈពេលបំរើការងារ :

- ការចាត់ទុកជារយៈពេលបំរើការងារ គឺគិតចាប់តាំងពីមន្ត្រី រាជការ កម្មកររដ្ឋដែល បានបញ្ចូលទៅក្នុងក្របខ័ណ្ឌ " រដ្ឋពេញសិទ្ធិ " រួចក្រោយមកចូលបំរើក្នុងកងយោធពលខេមរភូមិន្ទ ឬ ចាប់ពីពេលចូលបំរើក្នុងកងយោធពលខេមរភូមិន្ទជាប់រហូតដល់ពេលចូលនិវត្តន៍ ក៏ដូចជាត្រូវបានទទួលរបបបាត់បង់សមត្ថភាពការងារត្រូវបានគិតជាក់ស្តែងដូចខាងក្រោម ÷

_រយៈពេលធ្វើរដ្ឋបាល ភូមិ ឃុំ សង្កាត់ឬងជីវពលដែលមានប្រាក់ឧបត្ថម្ភ ។

_រយៈពេលមន្ត្រី រាជការ កម្មកររដ្ឋ ធ្វើការតាមក្រសួង ស្ថាប័នរដ្ឋនានា ឬរយៈពេល ទៅធ្វើកម្មសិក្សាក្នុង ឬ ក្រៅប្រទេស ។

_រយៈពេលមន្ត្រី រាជការ ធ្វើការងារក្រៅប្រទេស ។

_រយៈពេលបំរើការងារអតីតភាព តាមរបបសង្គម ។

_រយៈពេលបំរើការងារក្នុងចលនាតស៊ូ ។

_រយៈពេលជាប់មន្ទីរឃុំឃាំង ដោយគ្មានទោសកំហុស ។

_រយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ។

ខ_មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ :

- គឺជារយៈពេលដែលតម្រូវអោយមន្ត្រីរាជការ កម្មកររដ្ឋធ្វើការសាកល្បង ។

២_ការកំណត់ តំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព មានដូចខាង ក្រោម ÷

ក_តំបន់លំបាក :

-យោធិនបានបំពេញភារកិច្ចនៅតំបន់ដាច់ស្រយាល ឬ កោះ តំបន់គ្រុនចាញ់ តំបន់ព្រៃភ្នំ លំបាកដោយធាតុអាកាស ឬ លំបាកដោយជីវភាពរស់នៅ និងសមរភូមិប្រយុទ្ធ......។

ខ_ការងារគ្រោះថ្នាក់ :

យោធិនជាអាកាសយានិក ទ័ពជំនាញ " ឆ័ត្រយោង " ទ័ពវិស្វកម្ម " ជំនាញដោះមីន ទ័ពជំនាញផលិត ឬ ពិសោធន៍គ្រឿងផ្ទុះ ។

គ_ការខូចខាតសុខភាព :

យោធិនជានាវិក ជាងផ្សារដែក ជាងជួសជុលគ្រឿងចក្រធុនធ្ងន់ បុគ្គលិករ៉ាដា ជាងអគ្គិសនី អ្នកធ្វើការងារនៅអាគារជម្រៅផ្លូង អាគារចតឆ្នុះ និងមន្ទីរពិសោធន៍ " មន្ទីរពេទ្យ " ទំពជំនាញគីមីសាស្ត្រ ជំនាញកាំភ្លើងធំ អ្នកបើកបរគ្រឿងចក្រធុនធ្ងន់......។

ដើម្បីអនុវត្តអោយបានល្អ ហើយនិងមានប្រសិទ្ធភាពនោះ គឺក្រសួងការពារជាតិ ត្រូវធ្វើសេចក្តីកំណត់លំអិតអំពីលក្ខខ័ណ្ឌជាក់ស្តែង ។

មាត្រា ៣ ._ បៀវត្សរ៍ហានន្តរសក្តិត្រូវបានបូកបន្ថែមជាមួយ : ប្រាក់ហូបប្រចាំខែ ប្រាក់បំណាច់មុខងារ " បើមាន "ដើម្បីគិតប្រាក់សោធននិវត្តន៍ ហើយនិងបានទទួលប្រាក់បំណាច់តំបន់ " បើមាន "" គិតលើប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន " ។

មាត្រា ៤ ._ យោធិនទាំង ២ ភេទ ដែលមានគ្រប់លក្ខខ័ណ្ឌត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ហើយដូចមានចែងក្នុងមាត្រា ៥ និងមាត្រា ៦ ជំពូកទី ១ នៃព្រះរាជក្រម ។ ក្រៅពីទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ដូចដែលបានបញ្ជាក់ក្នុងប្រយោគទី ១ ខាងលើ យោធិនទាំង ២ ភេទត្រូវបានទទួលរបបមួយចំនួនទៀតដូចខាងក្រោម ÷

១_អ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ មានសិទ្ធិទទួលរបបដូចនៅពេលបំរើការងារ ។

២_ចំពោះនាយទាហានថ្នាក់ ឧត្តមសេនីយ ឬ វិរៈជន ដែលមានអ្នកបើកបររថយន្ត និងកងការពារ ត្រូវបានរាជរដ្ឋាភិបាលពិនិត្យ និងដោះស្រាយជាក់ស្តែង ។

៣_ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអាជ្ញាធរមានសមត្ថកិច្ចមានភារកិច្ច ពិនិត្យលទ្ធភាពជួយរកការងារធ្វើអោយនិវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារដែលមានលទ្ធភាពបន្តការងារទៀតបាន ដោយផ្អែកទៅតាមសំណើ និង ជំនាញរបស់សាម៉ីខ្លួន ។

មាត្រា ៥ ._ យោធិនទាំង ២ ភេទ មុនពេលចូលនិវត្តន៍អាចបានឈប់សំរាកច្បាប់ ដោយមានករណីចាំបាច់ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ទើបអនុញ្ញាតអោយ

ឈប់សំរាកបាន ដូចមានចែងក្នុងមាត្រា ៦ ចំណុច ២ ជំពូកទី ១ នៃព្រះរាជក្រម នឹងត្រូវបានកំណត់ដូចខាងក្រោម ÷

-យោធិនដែលមានឋានន្តរស័ក្តិពី ព្រិន្ទបាលឯក ចុះ ត្រូវបានឈប់សំរាក ៦ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ នាយចំណង់ និងអនុសេនីយ៍ ត្រូវបាន ឈប់សំរាក ៨ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ វរៈសេនីយ៍ ត្រូវបានឈប់សំរាក ១០ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ ឧត្តមសេនីយ៍ ត្រូវបានឈប់សំរាក១២ ខែ ។

នៅពេលទៅសំរាកច្បាប់ក្នុងប្រទេសត្រូវទទួលប្រាក់ធ្វើដំណើរ ប្រាក់ហូបចុក តាមផ្លូវ ទាំងទៅទាំងមក តាមការកំណត់របស់ក្រសួងការពារជាតិ ។

មាត្រា ៦ .– និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្លៀកពាក់ឯកសណ្ឋាន កងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ១ នៃព្រះរាជក្រម ដើម្បីជាកិត្តិយសក្នុងពិធីបុណ្យជាតិផ្សេងៗ ។ ការបើកផ្តល់ឯកសណ្ឋានកងយោធ ពលខេមរភូមិន្ទនេះ នឹងប្រព្រឹត្តទៅតាមការកំណត់របស់ ក្រសួងការពារជាតិ ។

មាត្រា ៧ .– សមត្ថកិច្ចនៃការសំរេចអោយបន្តការងារទៀត ឬ សំរេចអោយចូលនិវត្តន៍បាន ដូច មានចែងក្នុងមាត្រា ៨ ជំពូកទី ១ នៃព្រះរាជក្រម ព្រមទាំងអោយទទួលសោធនបាត់ បង់សមត្ថភាពការងារត្រូវបានកំណត់ដូចខាងក្រោម ÷

១_តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះយោធិនទាំង ២ ភេទ ចាប់ពី វរៈសេនីយ៍ទោ ឬ វរៈនារីទោចុះ ។

២_តាមអនុក្រឹត្យដោយមានសំណើពីរដ្ឋមន្ត្រីក្រសួងការពារជាតិចំពោះយោធិន ទាំង ២ ភេទថ្នាក់វរៈសេនីយ៍ឯក ឬ វរៈនារីឯក ។

៣_តាមព្រះរាជក្រឹត្យដោយមានសំណើពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះ យោធិនទាំង ២ ភេទ ថ្នាក់ឧត្តមសេនីយ៍ ។

៤_យោធិនទាំង ២ ភេទ ដែលបានបំពេញគ្រប់លក្ខខ័ណ្ឌ នៃរយៈពេល បំរើការងារ តែអាយុពុំទាន់គ្រប់ចូលនិវត្តន៍ មានសិទ្ធិចូលនិវត្តន៍ភ្លាម ។ ផ្ទុយទៅ វិញយោធិនទាំង ២ ភេទ ដែលចង់បន្តការងាររហូតគ្រប់លក្ខខ័ណ្ឌអាយុចូលនិវត្តន៍ ត្រូវសុំអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ជំពូកទី ២
របបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា ៨ .– យោធិនទាំង ២ ភេទ នៃកងយោធពលខេមរភូមិន្ទ ដែលអាចទទួលរបបបាត់បង់សមត្ថភាពការងារបានជាប្រចាំខែ លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ៩ និងមាត្រា ១២ ជំពូកទី ២ នៃព្រះរាជក្រម ។

អំពីរបៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាកការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព គឺត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា ២ ជំពូកទី ១ នៃអនុក្រឹត្យនេះ ។

មាត្រា ៩ .– ល័ក្ខខ័ណ្ឌជាក់ស្តែងនៃការគិត នូវលក្ខណៈបាត់បង់សមត្ថភាពការងាររបស់ យោធិនតាមថ្នាក់នីមួយៗ ដូចមានចែងក្នុងមាត្រា ១០ ជំពូកទី ២ នៃព្រះរាជក្រមត្រូវបានកំណត់ដោយប្រកាសរួមអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា ១០ .– បៀវត្សរ៍ឋានន្តរស័ក្តិត្រូវបានបូកបន្ថែមជាមួយ ប្រាក់ហូបប្រចាំខែប្រាក់បំណាច់មុខងារ "បើមាន" ដើម្បីគិតប្រាក់សោធនបាត់បង់សមត្ថភាពការងារ ហើយនិងបានទទួលប្រាក់បំណាច់តំបន់ " បើមាន " គិតលើប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ។

មាត្រា ១១ .– យោធិនទាំង ២ ភេទ ដែលអាចទទួលរបបបាត់បង់សមត្ថភាព ការងារជាប្រចាំខែបានលុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១២ និងមាត្រា ១៣ ជំពូកទី ២ នៃព្រះរាជក្រម ។

ក្រៅពីរបបដែលបានបញ្ជាក់ក្នុងប្រយោគទី ១ ខាងលើ យោធិនទាំង ២ ភេទត្រូវបានទទួលរបបដូចមានចែងក្នុងមាត្រា ៤ (ចំណុច ១ ២ ៣) និងមាត្រា ៦ ជំពូកទី ១ នៃអនុក្រឹត្យ នេះ ។

មាត្រា ១២ .– យោធិនបាត់បង់សមត្ថភាពការងារដែលគ្មានទីពឹងផ្អែក ដូចមានចែងក្នុងមាត្រា ១៣ (ចំណុច២) ជំពូកទី២ នៃព្រះរាជក្រម រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅ មជ្ឈមណ្ឌលរបស់រដ្ឋ ឬ និវត្តជន ចាស់ជរារស់នៅតែលតោលគ្មានទីពឹងផ្អែក ក៏មានសិទ្ធិដូចជនបាត់បង់សមត្ថភាពការងារដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ឬ សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ត្រូវកាត់យក ស្មើនឹង ៥០ ភាគរយ ដើម្បីធានាការហូបចុក បើសិនជាខ្វះខាតរដ្ឋ បំពេញបន្ថែម ។ ចំពោះ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ បើសិនទៅរស់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជំនួយកិច្ចការក្នុងផ្ទះ មិនបានបើកផ្តល់អោយឡើយ ។

មាត្រា ១៣ .– ក្រោយពេលនិវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ ទទួលមរណភាព គ្រួសារអ្នកទាំងនេះត្រូវបានដោះស្រាយរបបឧបត្ថម្ភមួយលើកគត់ដូចមានចែងក្នុងមាត្រា ១៤ ជំពូកទី ២ នៃព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន ។

ជំពូកទី ៣
សមត្ថកិច្ច នៃការគ្រប់គ្រង និង បើករបបសោធននិវត្តន៍ និង របបសោធនបាត់បង់សមត្ថភាពការងារ

មាត្រា ១៤ .– ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិ ត្រូវស្រង់បញ្ជីឈ្មោះយោធិនចូលនិវត្តន៍ និងយោធិនបាត់បង់សមត្ថភាពការងារ ជូនក្រសួងសេដ្ឋកិច្ច –ហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីបំរុងថវិកាក្នុងការបើកផ្តល់សោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាព ការងារ ។

-ការគ្រប់គ្រង និង បើកចែករបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបានបេឡាសោធន ។

-ក្រសួងការពារជាតិមានភារកិច្ចបើកប្រាក់ឧបត្ថម្ភ ១ លើក ជូនដល់និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារនៃកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ មុនពេលផ្ទេរទៅអោយក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ១៥ .– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច_ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន និងអភិបាលខេត្ត_ក្រុងទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ / ព្រះហស្តលេខា និងត្រា / នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២ / ហត្ថលេខា និង ត្រា / ហ៊ុន សែន

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ១១ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់វារីអគ្គិសនីស្ទឹងមេទឹក (មណាម) នៃព្រះរាជាណាចក្រកម្ពុជា

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
– យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
– យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់អង្គប្រជុំអន្តរក្រសួងស្តីពីគំរោងស្ថាបនាវារីអគ្គិសនីលើស្ទឹងមេទឹក (មណាម) នាថ្ងៃ ទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយមានឈ្មោះថា :«គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក(មណាម) នៃព្រះរាជាណាចក្រកម្ពុជា «ហៅកាត់ថា «គ.វ.ក» ។

មាត្រា ២ : គណៈគណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) មានសមាសភាពដូចខាងក្រោម :

១–ឯកឧត្តម **អ៊ុង ហឿត**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន	សហប្រធាន
២–ឯកឧត្តម **ទៀ បាញ់**	សហរដ្ឋមន្ត្រីក្រសួងការពារជាតិ	សហប្រធាន
៣–ឯកឧត្តម **សុខ អាន**	សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤–ឯកឧត្តម **វេង សេរីវុឌ្ឍ**	សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥–ឯកឧត្តម **ម៉ុក ម៉ារ៉េត**	រដ្ឋមន្ត្រីក្រសួងបរិស្ថាន	សមាជិក
៦–ឯកឧត្តម **ពូ សុធីរៈ**	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	សមាជិក
៧–ឯកឧត្តម **តាវ សេងហួរ**	រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
៨–ឯកឧត្តម **អ៊ុច គីមអាន**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩–ឯកឧត្តម **អ៊ឹម ឈុនលឹម**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
១០–ឯកឧត្តម **ស៊ុន ចាន់ថុល**	អគ្គលេខាធិការក្រុមប្រឹក្សា	

	អភិវឌ្ឍន៍កម្ពុជា	សមាជិក
១១–ឯកឧត្តម **ឆាយ ថន**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក

មាត្រា ៣ : គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) ត្រូវបានអនុញ្ញាតអោយមានក្រុមការងារជាអ្នកឯកទេស សំរាប់ជួយរាល់កិច្ចការពាក់ព័ន្ធ និង គំរោងស្ថាបនាវារីអគ្គិសនីនេះដែលមានសមាសភាពដូចតទៅ :

១–ឯកឧត្តម **ឃី តាំងលីម**	អនុប្រធានគណៈកម្មការជាតិទន្លេមេគង្គ	ប្រធាន
២–ឯកឧត្តម **លឹម គានហោ**	អគ្គនាយកធារាសាស្ត្រ	អនុប្រធាន
៣–លោក **អ៊ុច ថន**	អភិបាលរងខេត្តកោះកុង	សមាជិក
៤–លោក **ធីក គៀវិទុត្ថា**	ទីប្រឹក្សាក្រសួងមហាផ្ទៃ	សមាជិក
៥–វរៈសេនីយ៍ឯក **ខែត នរិទ្ធ**	នាយករង នាយកដ្ឋានវិស្វកម្ម នៃក្រសួងការពារជាតិ	សមាជិក
៦–លោក **សយ សុខា**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧–លោក **សុខ សាវ័ន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៨–លោក **ប៊ុន ណារិទ្ធិ**	តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	សមាជិក
៩–លោក **អ៊ុច គិរុន**	តំណាងក្រសួងបរិស្ថាន	សមាជិក
១០–លោក **ប៊ុច សុខែម**	តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	សមាជិក

ក្រុមការងារនេះមានសិទ្ធិបន្ថែមនូវសមាសភាពមន្ត្រីជំនាញជាជំនួយការតាមសេចក្តីត្រូវការចាំបាច់។

មាត្រា ៤ : គណៈកម្មការវារីអគ្គិសនីស្ទឹងមេទឹក (មណាម) មានភារកិច្ច :

១–ជំរុញការងារសិក្សាស្រាវជ្រាវកសាងឯកសារបច្ចេកទេស និង សេដ្ឋកិច្ច ស្តីពីគំរោងសាងសង់វារី អគ្គិសនីស្ទឹងមេទឹក (មណាម) ។

២–ធ្វើការចរចាជាមួយភាគីថៃពីលទ្ធភាពនៃការប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានអ៊ែក នៃស្ទឹងមេទឹក (មណោម) ដើម្បីជាផលប្រយោជន៍នៃប្រទេសទាំងពីរ ។

៣–ទំនាក់ទំនងស្វែងរកជំនួយពីអង្គការអន្តរជាតិ និងពីបណ្តាប្រទេសនានា ។

៤–ពិនិត្យសិក្សាជ្រើសរើសក្រុមហ៊ុនឯកជនដែលមានលទ្ធភាពធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសជាបឋម (Prefeasibility study) និងសិក្សាស្រាវជ្រាវអំពីលទ្ធភាពកសាងគំរោង (feasibility study) ។

៥–ពិនិត្យជ្រើសរើសក្រុមហ៊ុនដែលអាចមានលទ្ធភាពធ្វើវិនិយោគក្នុងការងារនេះ ។ រួចធ្វើរបាយការណ៍ពីលទ្ធផលរបស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

មាត្រា ៥ : ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធនិងសាមីជនមានភារកិច្ចទទួលអនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ១២ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោងការស្តារ និងកែលំអអាកាសយានដ្ឋានខេត្តសៀមរាប

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ ១០៩៤.៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុស្សារណៈយល់ដឹង ស្តីពីគំរោងការកែលំអអាកាសយានដ្ឋានសៀមរាប រវាងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥
- តាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១ : បង្កើតគណៈកម្មការដឹកនាំសំរបសំរួលគំរោងការមួយ (project coordination Steering Committee) ដើម្បីផ្តល់នូវការណែនាំលើគោលនយោបាយ និង សំរួលដោះស្រាយការងារអន្តរក្រសួងរាប់បញ្ចូលទាំងកិច្ចការសំរបសំរួលការរៀបចំផែនការ និង ការអនុវត្តនៃគំរោងការស្តារ និង កែលំអអាកាសយានដ្ឋានខេត្តសៀមរាប ។

មាត្រា ២ : គណៈកម្មការដឹកនាំសំរបសំរួលគំរោងការនេះ មានសមាសភាពដូចតទៅ ÷

-ឯកឧត្តម **ម៉ម សុផាណា**	អនុប្រធានអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន	សហប្រធាន
-ឯកឧត្តម **ម៉ុក សំអែល**	អនុរដ្ឋលេខាធិការអាជ្ញាធរអាកាសចរស៊ីវិល	សហប្រធាន
-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី		សមាជិក
-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន		សមាជិក
-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ		សមាជិក
-តំណាងក្រសួងផែនការ		សមាជិក
-តំណាងអាជ្ញាធរអប្សារា		សមាជិក

-តំណាងគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា សមាជិក

-តំណាងអាជ្ញាធរដែនដីខេត្តសៀមរាប សមាជិក

មាត្រា ៣ : គណៈកម្មការដឹកនាំសំរបសំរួលគំរោងការមានភារកិច្ចដូចតទៅ ÷

១ ផ្តល់នូវការណែនាំលើគោលនយោបាយ និង សំរួលដោះស្រាយការងារអន្តរក្រសួងពាក់ព័ន្ធ ដល់គំរោងការងារនេះរាប់បញ្ចូលទាំង :

-កិច្ចការសំរបសំរួលទាំងអស់

-ការរៀបចំផែនការ

-ការគ្រប់គ្រង និង ចាត់តាំងសមត្ថកិច្ច ដើម្បីអនុវត្តនូវភារកិច្ចទាក់ទងដល់ប្រតិបត្តិការរបស់ គំរោង

១ ត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ-ត្រីមាស ដែលរៀបចំឡើងដោយអង្គភាពអនុវត្តគំរោង (PIU) និងចុះពិនិត្យផ្ទៀងផ្ទាត់ដល់ទីកន្លែង ក្នុងកាលវេលាសមស្រប ។

៣ ត្រួតពិនិត្យលើស្ថានភាពហិរញ្ញវត្ថុរបស់គំរោង ដោយសហការជាមួយអ្នកពិគ្រោះការងារប្រចាំការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង តំណាងស្ថាប័នពាក់ព័ន្ធ និងមានរបាយការណ៍ប្រក្រតី ជូនទីស្តីការគណៈរដ្ឋមន្ត្រី ពិនិត្យ សំរេច ។

៤ ពិនិត្យ ពិចារណាលើលក្ខណៈសម្បត្តិនៃបេក្ខជនអ្នកពិគ្រោះ ឬ ទីប្រឹក្សាបរទេស ហើយលើក យោបល់ផ្តល់អនុសាសន៍សុំការសំរេចពីសហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤ : បង្កើតអង្គភាពអនុវត្តគំរោងការមួយ(Project Implementation Unit) ដើម្បីទទួលបន្ទុកផ្ទាល់ ការអនុវត្តន៍ , ការសំរបសំរួល និង តម្លើងរៀបចំប្រ... ការៈបរិក្ខាររបស់គំរោងការ ។ សមាសភាពនៃអង្គភាពអនុវត្តគំរោងការមានដូចតទៅ

-លោក **កែវ សាវឌ្ឍ** អគ្គនាយកអាជ្ញាធរអាកាសចរស៊ីវិល ប្រធាន

-តំណាងអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន សមាជិក

-តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

-តំណាងអាជ្ញាធរអាកាសចរស៊ីវិលផ្នែករដ្ឋបាល សមាជិក

-អ្នកពិគ្រោះបរទេសក្នុងការគ្រប់គ្រងគំរោងការ សមាជិក

មាត្រា ៥ : អង្គភាពអនុវត្តគំរោងមានភារកិច្ចដូចតទៅ ÷

-ទទួលអនុវត្តដោយផ្ទាល់សំរបសំរួល និង តម្លើងរៀបចំគំរោងការ ក្នុងការងាររដ្ឋបាលហិរញ្ញវត្ថុ និង បច្ចេកទេសជំនាញ ។

-ចុះជាប់ជាប្រក្រតី ពិនិត្យ-តាមដាន លើការងារពាក់ព័ន្ធទាំងអស់របស់គំរោងការ និង សរសេរ របាយការណ៍រៀងរាល់ខែ អំពីដំណើរប្រព្រឹត្តទៅ , ការរីកចំរើន , ចំណោទដែលកើតឡើង និង វិធីដោះស្រាយលើកជាយោបល់អនុសាន៍ជូនគណៈកម្មការដឹកនាំសំរបសំរួល ដើម្បីសុំយោបល់ សំរេចអនុម័តពីរាជរដ្ឋាភិបាល ។

-សហប្រតិបត្តិការលើការងារជាក់ស្តែង របស់គំរោងការជាមួយបណ្តាស្ថាប័នជំនាញដែលទាក់ទង ដើម្បីពិនិត្យផ្ទៀងផ្ទាត់លើរាល់លក្ខណៈបច្ចេកទេសទាំងបរិមាណ និង គុណភាព សមស្របតាមការកំណត់ ស្របតាមខ្នាតគំរូ និង បទដ្ឋានអន្តរជាតិក្នុងកិច្ចសន្យាជាមួយបណ្តាក្រុមហ៊ុនម៉ៅការ ។

មាត្រា ៦ : របនាសម្ព័ន្ធ និង សេម៉ា របស់គណៈកម្មការដឹកនាំសំរបសំរួល និង អង្គភាពអនុវត្តគំរោង សំរាប់អាកាសយានដ្ឋានសៀមរាប ត្រូវបានជូនភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ ទី ១ និង ទី២ ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាជ្ញាធរអាកាសចរស៊ីវិល - អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន-អាជ្ញាធរអប្សរា-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្ត សៀមរាប និង បណ្តាស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤២ អនក្រ.តត

ស្តីពីការផ្លាស់មន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានផ្លាស់លោក **ហោ ណាំបូរ៉ា** ទីប្រឹក្សាស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ និង ជំនួយការនៃតំណាង បេសកកម្មអចិន្ត្រៃយ៍ប្រចាំ ESCAP នៅទីក្រុងបាងកក អោយមកបំរើការងារនៅក្នុងប្រទេសវិញដោយចប់អាណត្តិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង លោក **ហោ ណាំបូរ៉ា** ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៣ អនក្រ.តត

ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចៅ្រន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ផ្ទេរលោក **នួន ឌីន** អគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា នៅហាណូយ អោយមកបំរើការងារក្នុងប្រទេស ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ លោក **នួន ឌីន** ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៤ អនក្រ.តត

ស្តីពីការកែសំរួលឋានន្តរសក្តិ និង ផ្តល់អត្តលេខយោធិន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជ រដ្ឋាភិបាល
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួលឋានន្តរសក្តិនាយទាហាន ថ្នាក់វរសេនីយឯក ក្នុងកងយោធពល ខេមរភូមិន្ទ លោក **ខែម ឆាន់** អភិបាលស្រុកជងទង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គ សេនាធិការនៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាមីខ្លួន

ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៥ អនក្រ.គត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគថវិកាកសាងស្ពាន និង ផ្លូវ នៅភូមិត្រពាំងធ្នូក ឃុំច្រៃស ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម នេះ ÷

ក–មេដាយ«ប្រាក់»ស្ថាបនាជាតិ :

១–លោកឧត្តមសេនីយ៍ត្រី **ម៉ុង សំផន** ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

ខ–មេដាយ«សំរិទ្ធ»ស្ថាបនាជាតិ :

១–លោកវរសេនីយ៍ឯក **សោម សាឌុំម** ទឹកប្រាក់ ៣.៧០០ ដុល្លារអាមេរិក

២–លោកវរសេនីយ៍ទោ **ឈួន ថាវរិន** ទឹកប្រាក់ ១.៥០០ ដុល្លារអាមេរិក

៣–អ្នកស្រី **យិន សាវី** ទឹកប្រាក់៣.៥០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និង ត្រា **ហត្ថលេខា និងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស»ស្ថាបនាជាតិជូនចំពោះលោកស្រី MARIKO OKA MURA ប្រធានសមាគម ASAC ដែលបានជួយសាងសង់សាលារៀន ០២ កន្លែង និងជួយប្រជារាស្ត្រ ក្នុងខេត្តកំពត អស់ទឹកប្រាក់សរុប ១២២.១០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគ ធនធានផ្ទាល់ខ្លួនជួយកសាងអាគារសិក្សា និងសំភារៈសិក្សានៅក្នុងខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយមាស ស្ថាបនាជាតិ :

១-លោកស្រី **គង់ ថន** នាមដើម **គីម ស៊ីដាទី** នៅសហរដ្ឋអាមេរិក បរិច្ចាគ ប្រាក់ ១០.០០០ ដុល្លារអាមេរិក

ខ-មេដាយសំរិទ្ធ ស្ថាបនាជាតិ :

១-លោក **ស្រី សឿន** និងភរិយា នៅភ្នំពេញ ទឹកប្រាក់ ៤៤៧៩,១៦ ដុល្លារអ៊ុយអេស

២-លោក **ស៊ េ គីមសឿន** និងភរិយា នៅភ្នំពេញ ទឹកប្រាក់ ៤៤៧៩,១៦ ដុល្លារអ៊ុយអេស

៣-លោក **ជា ឡុន** និងភរិយា នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ៤៥៥៥ ដុល្លារអ៊ុយអេស

៤-លោក **សោម សាន្ត** និងភរិយា នៅស្រុកចន្ទ្រា ទឹកប្រាក់ ៣៨៦១ ដុល្លារអ៊ុយអេស

៥-លោក **សែម ឈួរិន** និងភរិយា នៅស្រុកចន្ទ្រា ទឹកប្រាក់ ៣៨៦២ ដុល្លារអ៊ុយអេស

៦-លោក **ឆិត ភីម** នៅសហរដ្ឋអាមេរិក ទឹកប្រាក់
៣៦០០ ដុល្លារអ៊ុយអេស

៧-លោក **ឈាប សន** និងភរិយា នៅភ្នំពេញ ទឹកប្រាក់
៣.៩១៤.១៨០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណប្ញទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៤៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ បាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិជូនចំពោះលោក **តាន់ អ៊ុកណារ៉ាវ៉ាង** និងលោកស្រី **ឡុង ជឹម** ដែលមានចិត្តសប្បុរសបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១៥.០០០ ដុល្លារអាមេរិក សំរាប់កសាងមណ្ឌលសុខភាពនៅក្នុងឃុំស្មោ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្ថលេខា និងត្រា **ហត្ថលេខា និងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៥០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះអង្គភាព មន្ទីរក្រុមហ៊ុន និង អង្គការក្រៅរដ្ឋាភិបាលដែលបានបរិច្ចាគថវិកាចូលរួមចំណែកកសាងសំណង់ផ្សេងៗ ជាប្រយោជន៍សាធារណៈនៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

ក — មេដាយ « មាស » ស្ថាបនាជាតិ :

១–អង្គការមូលនិធិសង្គ្រោះកុមារ អូស្ត្រាលីនៅកម្ពុជាទឹកប្រាក់ ១០៨.០០០ ដុល្លារអាមេរិក
២–អង្គការមូលនិធិគាំទ្រ អ.ស.ប ទឹកប្រាក់ ៦០.០០០ –
៣–អង្គការកម្មវិធីស្បៀងអាហារពិភពលោក អង្ករ ១០.៨៩១.៤៤៧,៣៧ គីឡូក្រាម
៤–មន្ទីរសាធារណការនិងដឹកជញ្ជូន ទឹកប្រាក់ ៧២.៣៦០.០០០ រៀល
៥–តំបន់ប្រតិបត្តិការសឹករងកំពង់ចាម ទឹកប្រាក់ ២៩.៥៨០.០០០ –
៦–ក្រុមហ៊ុនមីដាជប៉ុន ទឹកប្រាក់ ២៣.៥៦២ ដុល្លារអាមេរិក
៧–អង្គការវិស្វករឥតព្រំដែន I.S.F ទឹកប្រាក់ ១២.៥៧០ –
៨–ក្រុមហ៊ុន **ឈូ នាងឈូ** ផលិតក្តារបន្ទះ ទឹកប្រាក់ ១០.០០០ –

ខ—មេដាយ « ប្រាក់ » ស្ថាបនាជាតិ :

១–សាលាស្រុកត្បូងឃ្មុំ ទឹកប្រាក់ ២១.៣៤៨.០០០ រៀល
២–សាលាស្រុកពញាក្រែក ទឹកប្រាក់ ១៩.៧៨៨.០០០ រៀល
៣–អង្គការវេដបាណា ទឹកប្រាក់២៤.១៦០.០០០ រៀល
៤–អង្គការស្ពានហុល្លង់ ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

គ—មេដាយ « សំរិទ្ធិ » ស្ថាបនាជាតិ :

១–ក្រុមហ៊ុនចំការកៅស៊ូក្រែកទឹកប្រាក់ ១២.៦៨៧.០០០ រៀល
២–សាលាឃុំអារក្សត្នោតទឹកប្រាក់ ១១.០០០.០០០ រៀល
៣–សាលាស្រុកព្រៃឈរទឹកប្រាក់ ៩.០០០.០០០ រៀល
៤–សាលាស្រុកកោះសូទិនទឹកប្រាក់ ៧.៦៩៥.២០៣ រៀល
៥–មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ទឹកប្រាក់ ៥.០០០.០០០ រៀល
៦–មន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល ទឹកប្រាក់ ៤.៤០០.០០០ រៀល

៧–សាលាស្រុកអូររាំងឪទឹកប្រាក់	៤.០០០.០០០ រៀល
៨–សាលាស្រុកស្រីសន្ធរ ទឹកប្រាក់	១.៣៧៤ ដុល្លារអាមេរិក
៩–មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទឹកប្រាក់	៣.០២៨.០០០ រៀល
១០–ឃុំកងតាណឹង ស្រុកកងមាសទឹកប្រាក់	៦.៧៦០.០០០ រៀល
១១–សាលាឃុំសំបួរមាស ស្រុកកំពង់ចាម ទឹកប្រាក់	៦.០៨០.០០០ រៀល
១២–ភូមិស្វងលិច ស្រុកត្បូងឃ្មុំទឹកប្រាក់	៣.០០០.០០០ រៀល
១៣–ភូមិកណ្តាលក្រែក ស្រុកពញាក្រែក ទឹកប្រាក់	៣.០៧៥.០០០ រៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល ខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ — **ព្រះហស្តលេខា និង ត្រា** — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — **ហត្ថលេខា និងត្រា** — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៥១ អនក្រ . តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនចំពោះលោក និង លោក ស្រី HORNG MUSKHUN ប្រធានក្រុមហ៊ុន CHIENTOR Company ដែលបានបរិច្ចាគថវិកា ចំនួន ១០.៥០០ ដុល្លារអាមេរិក សំរាប់សាងសង់អាគារសិក្សា ០១ ខ្នង នៅក្នុងវត្ត សាឡុង ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្ថលេខា និង ត្រា **ហត្ថលេខានិងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៥២ អនក្រ . តត

ស្តីពីការផ្ទេរក្របខ័ណ្ឌនាយទាហាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិ នៃ គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌ ចំពោះនាយទាហាន ÷

លោកវរសេនីយ៍ឯក **ឯម ស៊ាម** នាយទាហានរង់ចាំ អគ្គសេនាធិការ បច្ចុប្បន្នត្រូវបានទៅបំរើការងារនៅក្រសួងមហាផ្ទៃ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា ក៏ដូចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ០៦ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_ ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជា រដ្ឋមន្ត្រីស្តីទី ក្រសួងផែនការ ចាប់ពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃឯកឧត្តម **ជា ចាន់តូ** ត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ០៧ សសរ

ស្តីពីការបង្កើតក្រុមការងារសំរាប់ធ្វើការជាមួយ

ក្រុមការងារ សមាគមន៍អ៊ឺរ៉ុបលើបញ្ហានាំចេញ

សំលៀកបំពាក់ ទៅអ៊ឺរ៉ុប

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : បង្កើតក្រុមការងារមួយសំរាប់ធ្វើការជាមួយក្រុមការងារសហគមន៍អឺរ៉ុប លើបញ្ហានាំចេញសំលៀកបំពាក់ពីព្រះរាជាណាចក្រកម្ពុជាទៅសហគមន៍អឺរ៉ុប ក្នុងប្រព័ន្ធអនុគ្រោះពន្ធ GSP ដែលមានសមាសភាពដូចខាងក្រោម ÷

១–អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	ជាប្រធាន
២–តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៣–តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៤–តំណាងក្រសួងផែនការ	សមាជិក
៥–តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	សមាជិក
៦–តំណាងគណៈកម្មាធិការជាតិវិនិយោគទុន	សមាជិក
៧–ប្រធានទីចាត់ការគយ	សមាជិក
៨–ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស	ស[illegible]
៩–ប្រធានសមាគមរោងចក្រកាត់ដេរ	សមាជិ[illegible]
១០–មន្ត្រីក្រសួងពាណិជ្ជកម្ម	លេខាធិការ

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ច :

- រៀបចំបញ្ជីឯកសារ និងស្ថិតិចាំបាច់តាមក្រសួងនីមួយៗ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយ ឯកសារដែលសហគមន៍អឺរ៉ុបបានទទួល ។

– ត្រៀមរបាយការណ៍ចាំបាច់ សំរាប់ពន្យល់តំណាងសហគមន៍អឺរ៉ុប និងការងារ របស់ក្រសួងនីមួយៗ ដែលពាក់ព័ន្ធដល់កានាំចេញទំនិញតាមប្រព័ន្ធអនុគ្រោះពន្ធ GSP ។

– ពិភាក្សារកវិធានការបំបាត់ការក្លែងបន្លំវិញ្ញាបនប័ត្រប្រភពដើមទំរង់ A ។

– ខិតខំពន្យល់អោយសហគមន៍អឺរ៉ុប យល់ពីការលំបាករបស់កម្ពុជា ដើម្បីអោយ គេយោគ យល់ដល់កម្ពុជា លើការអនុវត្តមិនទាន់បានល្អ នូវបទបញ្ញត្តិនានាស្តីពី ការនាំចេញតាម ប្រព័ន្ធ GSP ។

ប្រការ ៣ : សមាជិកទាំងអស់ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : នៅពេលពិភាក្សា បើមានជួបការលំបាក ត្រូវសុំមតិណែនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម ក្នុងករណីចាំបាច់ត្រូវសុំមតិណែនាំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ រដ្ឋមន្ត្រី ក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អគ្គលេខាធិការវិនិយោគទុន រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានឈ្មោះ ក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេច នេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ០៨ សសរ

ស្តីពីការបង្កើតគណៈកម្មការបង្ក្រាបការផលិត

និង នាំចូលរូបិយវត្ថុក្លែងក្លាយគ្រប់ប្រភេទ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការបង្ក្រាបការផលិត និង នាំចូលរូបិយវត្ថុក្លែងក្លាយគ្រប់ប្រភេទ រួមមាន សមាសភាពដូចខាងក្រោម ÷

១–សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ តំណាង	ប្រធាន
២–តំណាងអគ្គសេនាធិការ	អនុប្រធាន
៣–តំណាងធនាគារជាតិនៃកម្ពុជា	អនុប្រធាន
៤–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥–តំណាងក្រសួងការពារជាតិ	សមាជិក
៦–តំណាងកងរាជអាវុធហត្ថជាតិ	សមាជិក

៧–តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

ប្រការ ២ : គណៈកម្មការបង្ក្រាបការផលិត និងនាំចូលរូបិយវត្ថុក្លែងក្លាយគ្រប់ប្រភេទ ត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ហើយមានភារកិច្ចចាត់អោយ ÷

– ស្រាវជ្រាវ អំពីប្រភព នៃការផលិត និង កន្លែងទទួលដោះដូររូបិយវត្ថុក្លែងក្លាយគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា

– ស្រាវជ្រាវរកមុខសញ្ញា ទីតាំង និង ឧបករណ៍ផលិត ព្រមទាំងខ្សែរយៈទាក់ទងធ្វើសកម្មភាពផលិត និង នាំចូលរូបិយវត្ថុក្លែងក្លាយ ។

– រៀបចំឯកសារនិងវត្ថុតាងសព្វគ្រប់ដើម្បីបញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ ។

– ទំនាក់ទំនងជាមួយ INTERPOL នៃប្រទេសនានា ដើម្បីអោយគេសហការចាប់ជនល្មើស ឬ រកទីតាំងផលិត និង កន្លែងដោះដូររូបិយវត្ថុក្លែងក្លាយនៅក្រៅប្រទេស ។

– អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

ប្រការ ៣ : ប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃ អោយបង្កើតអនុគណៈកម្មការជំនាញមួយ ដើម្បីជំនួយការផ្ទាល់អោយគណៈកម្មការនេះ ។ សមាសភាព និង ភារកិច្ច របស់អនុគណៈកម្មការជំនាញ អាស្រ័យដោយក្រសួងមហាផ្ទៃជាអ្នកសំរេចជ្រើសរើស និង កំណត់ ។

ប្រការ ៤ : ប្រធានគណៈកម្មការ ត្រូវកោះប្រជុំ ទៀងរាល់ដំណាច់ខែនីមួយៗ ហើយត្រូវរាយការណ៍លទ្ធផលការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាល ។ ប្រធានគណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងមហាផ្ទៃ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

លិខិតសរសើរ លេខ ០៩ សសរ

រាជរដ្ឋាភិបាលកម្ពុជា

* * *

សូមថ្លែងអំណរសរសើរចំពោះ ឯកឧត្តម **នួច ការនុន** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានពិសោធន៍ដោយជោគជ័យក្នុងការយកប្រភពទឹកក្រោមដីតាមវិធីអណ្តូងបុក មកបំរើអោយវិស័យកសិកម្ម នៅស្រុក កំពង់ត្របែក ខេត្តព្រៃវែង ។

រាជរដ្ឋាភិបាលកម្ពុជា សូមចាត់ទុកស្នាដៃ ដ៏ថ្លៃថ្លានេះ ជាសក្ខីភាព នៃទឹកចិត្តស្នេហាជាតិ ក្នុងការស្តារ និង អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ។

នាយករដ្ឋមន្ត្រីទី ១ — **ព្រះហស្តលេខា និង ត្រា** — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — **ហត្ថលេខា និងត្រា** — **ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ១០ សសរ

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការនារី

សំរេច

ប្រការ ១ : តែងតាំងឯកឧត្តម **នួច ភានុន** រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការ ស្តីទី នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារីនៅក្នុងឱកាសដែលឯកឧត្តម **កៀត សុគន្ធ** អញ្ជើញទៅ បំពេញបេសកកម្មនៅឯបរទេស ចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **នួច ភានុន** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ១១ សសរ

ស្តីពីការបង្កើតគណៈកម្មការពិនិត្យការសុំពន្យារពេលចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

– យោងតាមសភាពការណ៍ចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយដើម្បីពិនិត្យការសុំពន្យារពេលចូលនិវត្តន៍ របស់មន្ត្រីរាជការស៊ីវិល ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាសហប្រធាន

២–ឯកឧត្តម **នូវ កាន់នុន** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាសហប្រធាន

៣–ឯកឧត្តម **ប្រាក់ សុខ** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាអនុប្រធាន

៤–ឯកឧត្តម **ជា ម៉េងឈាង** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៥–ឯកឧត្តម **ហួន ថែម** អនុរដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ជាសមាជិក

៦–ឯកឧត្តម **ម៉ម ប៊ុនហេង** អនុរដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចធ្វើការពិនិត្យសិក្សា លើគោលការណ៍ នៃការពន្យារពេលចូល និវត្តន៍ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុលើសពី ៥៥ ឆ្នាំ ហើយរាយការណ៍ និងផ្តល់យោបល់លើករណីនីមួយៗ ជូនរាជរដ្ឋាភិបាលពិនិត្យ សំរេច ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋានដែល ពាក់ព័ន្ធ និង ឯកឧត្តមដែលមាននាមក្នុង ប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

III - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ១៩០ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស្រី ចាន់ណារី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៤៦២៣០ ភ.ព ចុះថ្ងៃទី ៣០_៦_៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៨០០បេ១៥ ផ្លូវជាតិលេខ ៥ ក្រុមទី ៧ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៦ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩១ ឧក.ប្រកចុះ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉ៅ វ៉ាស៊ីន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០២៩៦០ក.ធ ចុះថ្ងៃទី ១៩_១០_៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិក្ដី ឃុំព្រៃតាហ៊ូ ស្រុក ស្ទឹងសែន ខេត្តកំពង់ធំ បន្តដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ម៉ៅ វ៉ាស៊ីន** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្ត: ទ្វារ បង្អួច តុ ទូ គ្រែ និង កៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាង ផ្ញើមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ធំ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩២ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **គីម ឆ៊ុក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១០៤៤៩២ ភ.ព ចុះថ្ងៃទី ២៦_៤_៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦ ក្រុមទី ៤៣ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុងទីតាំងភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ម្ល ដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ១៩៣ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ៅ ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៩៩៨៥ ក.ស្ត. ចុះថ្ងៃទី ០៣_៤_៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រាំងខ្នាយ ឃុំ តាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ម៉ៅ ហេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩៤ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លឹម ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៨៩៣៥ ភ.ព ចុះថ្ងៃទី ៣០_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦១ ក្រុមទី ៤៣ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុងទីតាំងក្រុមទី ២ ភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩៥ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឃុត ស៊ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២៤១៣២ ភ.ព ចុះថ្ងៃទី ០៩_០១_៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧៧អ៊ី០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុងទីតាំងភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩៦ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **រ៉េង យ៉ាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០២០៥៩ ក.ធ ចុះថ្ងៃទី ១១_១០_៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិស្លាកែត ឃុំព្រៃតាហ៊ូ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បន្តដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទី តាំងភូមិគ្គី ឃុំព្រៃតាហ៊ូ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។

ប្រការ ២ : អ្នកស្រី **រ៉េង យ៉ាត** ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ ទ្វារ បង្អួច តុ ទូ គ្រែ និង កៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាង ផ្ញើមក ក្រសួង តាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ធំ ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩៨ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **លី អៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណ លេខ ២៨៣៤៥០ ក.ណ ចុះថ្ងៃទី ២៣_៦_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ២ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវ កំលាំង ២៤សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **លី អៀង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបាន កំណត់ ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩៩ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាច ស្រួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណ លេខ ៣២៨០០៤ ក.ណ ចុះថ្ងៃទី ២៨_៤_៩០ អាស័យដ្ឋានបច្ចុប្បន្ន

ភូមិលេខ ១ ឃុំ ពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡាច ស្រួយ** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ២០០ ផក.ប្រកចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **គីម ទី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០៨២៧៦ប.ជ ចុះថ្ងៃទី ១៣_៦_៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បើក ដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៥១សេះ នៅក្នុងទីតាំងភូមិគោកព្នៅ ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : លោក **គីម ទី** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២០១ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ទេព សំអាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤២៦៨៤ ភ.ព ចុះថ្ងៃទី ២៧_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៤២អឺ០ ផ្លូវ លេខ ១៧៤ សង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្ម តូចផលិតជីតីមី ១៦_២០_០០ នៅក្នុងទីតាំងភូមិ ខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានី ភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២០៥ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឈុន ហួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៩៤៣៣១ ភ.ព ចុះថ្ងៃទី ០៩_១១_៩០ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១២ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុងទីតាំង ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២០៦ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ខុច សម្បត្តិ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣១៩៩៦៣ ភ.ព ចុះថ្ងៃទី ២៤_៩_៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៩អ៊ី០ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុង ទីតាំងភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២០៧ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **កែវ ខុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១០៤៤៩៣ ភ.ព ចុះថ្ងៃទី ២៦_៤_៨៥ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦ ក្រុមទី ៤៣ សង្កាត់ បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ_ក្បឿង នៅក្នុង ទីតាំងភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ឧស្សាហកម្ម រ៉ែ និង ថាមពល
ពូ សុធីរៈ

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៧៨ អយក. ប្រក

ប្រកាស

ស្តីពីការពង្រីក អនុវិទ្យាល័យស្ទោង ទៅជា

វិទ្យាល័យស្ទោង ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ_ច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់ រំចំនេះទូទៅ
- យោងលិខិតរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡា លេខ ៩០២ អកធ. មស ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តកំពង់ធំ
- តាមសំណើរបស់នាយកដ្ឋានចំនេះទូទៅនិង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យស្ទោង ទៅជា " **វិទ្យាល័យស្ទោង** " ចាប់ពីឆ្នាំសិក្សា ១៩៩៥_៩៦ តទៅ នៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ។

ប្រការ ២ : វិទ្យាល័យ ស្ពោង ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗទៀតមួយចំនួន តាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក នាយករង នៃវិទ្យាល័យ ។

ប្រការ ៤: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ នាយកវិទ្យាល័យស្ពោង មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៨៤ អយក.ប្រក

ប្រកាស

ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ទឹកឃ្លាំង

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_ បានឃើញក្រឹត្យ_ច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់ រំចំនេះទូទៅ

_ បានពិនិត្យលិខិតស្នើសុំរបស់នាយកសាលាបឋមសិក្សាទឹកឃ្លាំងលេខ ១៨ បទឃ. ចុះថ្ងៃទី ២០_ ១២_១៩៩៥ និងលិខិតរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ លេខ ៥៧ ខន២/៩៥ ចុះថ្ងៃទី ៥ កក្កដា ១៩៩៥ ។

_ តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅនិង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្តាលប្តូរឈ្មោះ សាលាបឋមសិក្សា ទឹកឃ្លាំង នៅឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល មកជា "សាលាបឋមសិក្សា **ហ៊ុន សែន** ទឹកឃ្លាំង "វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥_៩៦ នេះតទៅ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : មន្ទីរក្រសួងអប់រំ យុវជននិងកីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត កណ្តាល ការិយាល័យ អប់រំ យុវជន និង កីឡាស្រុកល្វាឯម នាយកសាលាបឋម សិក្សា **ហ៊ុន សែន** ទឹកឃ្លាំង មាន ភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៨៦ អយក.ប្រក

ប្រកាស

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យកោះសូទិន ទៅជាអនុវិទ្យាល័យ
" សាយ ឈុំ កោះសូទិន" ស្ថិតនៅក្នុងស្រុក
កោះសូទិន ខេត្តកំពង់ចាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ [illegible] ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បា[illegible]ក្រឹត្យ_ច្បាប់លេខ ៣០ ក្រប. ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តី[illegible]អប់រំចំនេះទូទៅ
- [illegible]ទិតស្នើ [illegible]របស់គណៈកម្មការសមាគមមាតាបិតាសិស្សអនុវិទ្យាល័យកោះសូទិន ដែ[illegible]នយោបល់ឯកភាពពីមន្ទីរ អប់រំ យុវជន និងកីឡា និងអភិបាលខេត្ត កំពង់ចាម
- តា[illegible]បល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅនិង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះ អនុវិទ្យាល័យកោះសូទិន បច្ចុប្បន្ន ទៅជា " អនុវិទ្យាល័យ **សាយ ឈុំ** - កោះសូទិន " ចាប់ពីឆ្នាំសិក្សាឆ្នាំ ១៩៩៥_៩៦ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបាត់តាំង និងប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរ អប់រំ យុវជននិងកីឡា ខេត្តកំពង់ចាម និង នាយកអនុវិទ្យាល័យ **សាយ ឈុំ** - កោះសូទិន មាន ភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

* * *

ៗ២៣៣